-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤៦៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការបញ្ចប់អាណត្តិបេសកកម្មមន្ត្រីការទូតជាន់ខ្ពស់

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបញ្ចប់មុខងារ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០១ ស្តីពី លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា ១ : ត្រូវបាន**ផ្លាស់**មន្ត្រីរាជការ ចំនួន ០២រូប **ចូលប្រទេស** ដោយត្រូវចប់អាណត្តិបេសកកម្ម ៖

១- លោក **ផន ពៅ** បច្ចុប្បន្ន **អគ្គកុងស៊ុល** នៃព្រះរាជាណាចក្រកម្ពុជាប្រចាំទីក្រុងហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន

២- លោក **ឡុង សុធីរា** ទីប្រឹក្សានៃស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសជប៉ុន។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមេសា ឆ្នាំ ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៦៣ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបញ្ចប់មុខងារ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខនស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងមន្ត្រីរាជការចំនួន **០២រូប** របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ៖

១. លោក **ស៊ិន ស៊ីយ៉ា** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានពិធីការនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជា **អគ្គកុងស៊ុល** នៃព្រះរាជាណាចក្រកម្ពុជាប្រចាំទីក្រុងហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន

២. លោក **ស៊ុយ តិច** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានអាហ្វ្រិក-មជ្ឈិមបូព៌ា នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជា **ទីប្រឹក្សា** នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសជប៉ុន។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមករា ឆ្នាំ ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល៖</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍
លេខ.០១..ស.ណ.ន

រាជធានីភ្នំពេញ,ថ្ងៃទី១៦ ខែឧសភាឆ្នាំ២០១៧

សេចក្តីណែនាំ

ស្តីពី

ការពង្រឹងវិធានការការពារសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាព សម្រាប់ដំណើរការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី ៤ នៅថ្ងៃអាទិត្យ ទី០៤ ខែ មិថុនា ឆ្នាំ ២០១៧

គិតមកដល់ពេលបច្ចុប្បន្ននេះ ការរៀបចំដំណើរការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី ៤ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០១៧ ខាងមុខ បានប្រព្រឹត្តទៅដោយរលូន និងទទួលបានលទ្ធផលមួយជំហានដោយពុំមានសភាពការណ៍អ្វីធំដុំកើតឡើង ជះឥទ្ធិពលប៉ះពាល់គួរកត់សម្គាល់ឡើយ ក្នុងនោះបានរៀបចំការចុះឈ្មោះបោះឆ្នោតដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ប្រកបដោយសុវត្ថិភាព និងបានប្រកាសលទ្ធផលជាផ្លូវការ ដែលមានប្រជាជនសរុប ស្មើនឹង ៨១.៣៨ % នៃចំនួនប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត បានចុះឈ្មោះបោះឆ្នោត ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានដំណើរការចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត និងបានបិទផ្សាយបញ្ជីបេក្ខជនផ្លូវការនៅតាមគណៈកម្មការឃុំ-សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) រួចហើយ ដែលក្នុងនោះមានគណបក្សនយោបាយចំនួន១២ ចូលរួមប្រកួតប្រជែង និងកំពុងបន្តដំណើរការកិច្ចការជាច្រើនទៀតតាមប្រតិទិន ដើម្បីឆ្ពោះទៅកាន់ការបោះឆ្នោតតាមការគ្រោងទុក ។

អាស្រ័យហេតុនេះ ដើម្បីធានាឲ្យកាន់តែល្អប្រសើរនូវសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី ៤ ឆ្នាំ២០១៧ នាពេលខាងមុខនេះ គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ សូមធ្វើការណែនាំដល់គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ សហការជាមួយ គ.ជ.ប ឬនិងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដូចខាងក្រោម ៖

១. គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី-ខេត្ត និងក្រុង-ស្រុក-ខណ្ឌ ដែលជាក្បាលម៉ាស៊ីនដឹកនាំយន្តការ-រចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតអចិន្ត្រៃយ៍នៅហ្នឹងកន្លែងត្រូវបន្តយកចិត្តទុកដាក់ដឹកនាំការងាររក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ជាពិសេស ដឹកនាំជំរុញការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ឲ្យក្លាយជាយុទ្ធនាការមួយព្រមៗគ្នាគ្រប់ឃុំ-សង្កាត់ទូទាំងប្រទេស ក្នុងគោលបំណងកៀរគរគ្រប់សមាសភាពទាំងអស់ក្នុងសង្គមចូលរួមឲ្យបានសកម្ម ។

២. ត្រូវយកចិត្តទុកដាក់ខិតខំស្រាវជ្រាវ ស៊ើបអង្កេតឲ្យបានហ្មត់ចត់រាល់បទល្មើសនានា ដែលកើតឡើង ជាពិសេស បទល្មើសព្រហ្មទណ្ឌដែលមានការចោទប្រកាន់ពាក់ព័ន្ធផ្នែកនយោបាយ និងឧបទ្ទវហេតុនានាដែលពាក់ព័ន្ធដល់បរិយាកាសនយោបាយ ដូចជាការគំរាមកំហែង ការបំភិតបំភ័យ ឬការទម្លាក់ស្លាក ផ្តួលរំលំស្លាក ការលាបពណ៌ផ្សេងៗលើស្លាកគណបក្សនានា ដើម្បីស្វែងរកចាប់ខ្លួនជនប្រព្រឹត្តបទល្មើសយកទៅផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

៣. ត្រូវចាត់វិធានការសកម្មក្នុងការប្រមែប្រមូលព័ត៌មានពីគ្រប់ប្រភព ដើម្បីពិចារណា វិភាគវាយតម្លៃសន្និដ្ឋានរាល់ហេតុការណ៍ដែលកើតឡើង ពិសេសយកចិត្តទុកដាក់រាល់ទិន្នន័យទាំងអស់ ដែលពាក់ព័ន្ធដល់សន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពនៃកិច្ចដំណើរការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៤ ឆ្នាំ២០១៧ ។ ត្រូវយកចិត្តទុកដាក់ក្តាប់ជាប់រាល់បាតុភាពទំនាស់ផ្សេងៗ ក្នុងប្រជាពលរដ្ឋ ការប្រមូលផ្តុំតវ៉ា ឬការធ្វើបាតុកម្ម កូដកម្មនានារបស់កម្មករ និងប្រជាពលរដ្ឋ ដោយត្រូវខិតខំសម្របសម្រួលដោះស្រាយ មិនទុកឲ្យមានផលប៉ះពាល់ដល់ការបោះឆ្នោតនាថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០១៧ ខាងមុខនេះ ។

៤. គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់លំដាប់ថ្នាក់ និងអាជ្ញាធរមានសមត្ថកិច្ច ត្រូវបន្តសហការចាត់វិធានការការពារសន្តិសុខ សុវត្ថិភាពជូនគ្រប់តំណាងឬភ្នាក់ងារ និងបេក្ខជនគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត អ្នកសង្កេតការណ៍ជាតិ-អន្តរជាតិ និងប្រជាពលរដ្ឋដែលត្រូវចូលរួមក្នុងដំណើរការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៤ ឆ្នាំ២០១៧ ឲ្យបានមធ្យ័តបំផុតតាមដែនសមត្ថកិច្ចរបស់ខ្លួន ។

៥. ត្រូវបន្តយកចិត្តទុកដាក់សហការរៀបចំ និងចាត់វិធានការការពារសន្តិសុខ សុវត្ថិភាព នៅគ្រប់គោលដៅសំខាន់ៗជាអាទិ៍ ទីកន្លែងជួបជុំ ទីស្នាក់ការគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឧបករណ៍មធ្យោបាយ សម្ភារឃោសនា ទីតាំងរក្សាទុក ឬក្បួនដឹកជញ្ជូនសម្ភារ និងឯកសារបោះឆ្នោតរបស់ គ.ជ.ប ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

៦. ត្រូវយកចិត្តទុកដាក់ផ្តល់សេវាសន្តិសុខដោយស្មើភាពគ្នា ជូនគ្រប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតទាំងអស់ ជាពិសេស ក្នុងអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោត ត្រូវផ្តោតសំខាន់លើការបែងចែកកម្លាំងការពារគ្រប់ក្បួនឃោសនាបោះឆ្នោត ការពារនៅជុំវិញបរិវេណ នៃអង្គពិធីឃោសនាដោយធានារក្សាឲ្យបានសណ្តាប់ធ្នាប់សាធារណៈ សណ្តាប់ធ្នាប់ចរាចរណ៍ ព្រមទាំងបរិយាកាសនយោបាយល្អ គ្មានការបំភិតបំភ័យ ការគំរាមកំហែង និងអំពើហិង្សា ឬការបង្កចលាចល ឬការអុកឡុកវឹកវរខានផ្សេងៗ ។

៧. គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់លំដាប់ថ្នាក់ និងអាជ្ញាធរមានសមត្ថកិច្ច ត្រូវសហការឲ្យបានល្អជាមួយគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដើម្បីធានាសន្តិសុខ សណ្តាប់ធ្នាប់នៅថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ២០១៧ ដែលជាថ្ងៃស្ងប់ស្ងៀម ឲ្យបានត្រឹមត្រូវតាមច្បាប់ស្តីពីការបោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតរបស់ គ.ជ.ប ។ ភ្នាក់ងារសន្តិសុខបោះឆ្នោតសហការជាមួយប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតធានាឲ្យបានដាច់ខាតសន្តិសុខការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងត្រូវអនុវត្តឲ្យបានត្រឹមត្រូវតាមបទបញ្ជា និងនីតិវិធីដែលបានកំណត់ដោយ គ.ជ.ប ។

៨. គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់លំដាប់ថ្នាក់ ត្រូវរៀបចំឲ្យមានក្រុមប្រចាំការអចិន្ត្រៃយ៍ ដើម្បីទទួលព័ត៌មាន និងដោះស្រាយព័ត៌មានពាក់ព័ន្ធដល់ការបោះឆ្នោត ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។ ទន្ទឹមនោះត្រូវរៀបចំឲ្យមានក្រុមប្រតិកម្មរហ័ស ដើម្បីឆ្លើយតបចំពោះបាតុភាព ឬឧបទ្ទវហេតុផ្សេងៗ ជៀសវាងការកេងចំណេញខាងផ្នែកនយោបាយ ឬក្នុងគោលបំណងបំផ្លាញការបោះឆ្នោត ។

៩. គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់លំដាប់ថ្នាក់ ត្រូវយកចិត្តទុកដាក់ចាត់ចែងអនុវត្តឲ្យបានហ្មត់ចត់នូវផែនការអន្តរស្ថាប័នលេខ០០៩ ផក/១៦ ចុះថ្ងៃទី ១៩-០៥-២០១៦ របស់ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និង គ.ជ.ប ស្តីពីកិច្ចការពារការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩ និងត្រូវចាត់ចែងរៀបចំឲ្យមានការប្រជុំរៀនសូត្រ ណែនាំ ដល់ភ្នាក់ងារសន្តិសុខបោះឆ្នោត និងមន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធឲ្យយល់ដឹងអំពីច្បាប់ បទបញ្ជា និងនីតិវិធីបោះឆ្នោត ព្រមទាំងឲ្យអនុវត្តបានត្រឹមត្រូវ ដើម្បីធានាបរិយាកាសបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងគ្មានការគំរាមកំហែងដែលអាចទទួលយកបាន ។

១០. គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី-ខេត្ត ត្រូវធានារបាយការណ៍ឲ្យបានទៀងទាត់ជារៀងរាល់ថ្ងៃចាប់ពីពេលនេះតទៅ និងមួយថ្ងៃ ០២ ដង (ព្រឹកម៉ោង ០៨.០០ និងរសៀលម៉ោង ១៦.០០) ចាប់ពីថ្ងៃចាប់ផ្តើមយុទ្ធនាការឃោសនាបោះឆ្នោត រហូតដល់ការបោះឆ្នោតបានចប់សព្វគ្រប់ជាស្ថាពរ លើកលែងករណីបន្ទាន់ជះឥទ្ធិពលដល់ផ្នែកនយោបាយត្រូវរាយការណ៍ជាវិសាមញ្ញ ជូនមកលេខាធិការដ្ឋាននៃ គ.ស.អ ដើម្បីមានវិធានការដោះស្រាយសមស្រប និងទាន់ពេលវេលា ។

ទទួលបានសេចក្តីណែនាំនេះ សូមគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី-ខេត្ត សមត្ថកិច្ចពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ និងភ្នាក់ងារសន្តិសុខបោះឆ្នោត ចាត់វិធានការអនុវត្តឲ្យមានប្រសិទ្ធភាព ។

ប្រធានគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍

សម្តេចក្រឡាហោម ស ខេង

ចម្លងជូន ៖

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងការពារជាតិ
- ក្រសួងមហាផ្ទៃ
- គ្រប់សមាជិករបស់ គ.ស.អ
- លេខាធិការដ្ឋាននៃ គ.ស.អ
- អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស
- គ្រប់គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី-ខេត្ត
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.........សហវ.

ប្រកាស
ស្តីពី
ការបង្កើតនិងតែងតាំងក្រុមលទ្ធកម្ម នៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តពោធិ៍សាត់

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.

ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីនីតិវិធី នៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ. បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសារធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងដាក់ឱ្យអនុវត្តអង្គភាពថវិកា
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញប្រកាសលេខ ៨៥៦ សហវ.ប្រក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការរៀបចំនិងចាប់ផ្តើមអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ ១៣៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការអង្គភាពថវិកា របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ២៣៧ សហវ.ប្រក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការរៀបចំថវិការកម្មវិធី
- បានឃើញប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ៥៥៨ សហវ.ប្រក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការបង្កើតនិងតែងតាំងក្រុមលទ្ធកម្មនៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត
- បានឃើញប្រកាសលេខ ១៨៤២ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិ ជូនប្រធានអង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

ប្រការ១.-

ត្រូវបានបង្កើតនិងតែងតាំងក្រុមលទ្ធកម្មនៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តពោធិ៍សាត់ ដូចខាងក្រោម÷

១. លោក **ស៊ុន ហោច**	ប្រធានមន្ទីរ	ជាប្រធាន
២. លោក **ឯក ម៉ុណ្ណារ៉ាត់**	អនុប្រធានមន្ទីរ	ជាអនុប្រធាន
៣. លោក **តុន តារ័ត្ន**	មន្ត្រីការិយាល័យលទ្ធកម្មសាធារណៈ	ជាសមាជិក
៤. លោក **មុយ បញ្ញា**	មន្ត្រីការិយាល័យបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ	ជាសមាជិក
៥. លោកស្រី **ឆេត សុខា**	មន្ត្រីការិយាល័យបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ	ជាសមាជិក។

២ Phar...

ប្រការ២.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៣.-

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកវិទ្យាស្ថាន ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្ត ប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ[illegible] ឆ្នាំ២០១៧

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល៖

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាមីអង្គភាពថវិកា
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ............សហវ.......

ប្រកាសអន្តរក្រសួង
ស្តីពី
ការតែងតាំងរដ្ឋលេខាធិការប្រចាំការ
របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

ទេសរដ្ឋមន្ត្រី **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**	**ទេសរដ្ឋមន្ត្រី** **រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែ មេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/៩៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្ម មាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧

- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា ៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញប្រកាសលេខ ២៥៤ MIH / 2016 ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការដាក់ឱ្យអនុវត្តអង្គភាពថវិកា រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិកា នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឲ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាបេស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឲ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួល ប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៤ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យ បុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម

សម្រេច

ប្រការ១._ ត្រូវបានតែងតាំងមន្ត្រីរាជការ នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលមានសមាសភាពដូចខាងក្រោម ៖

១-លោក **វ៉ែន លន់**	ឋានៈជាអនុប្រធានការិយាល័យ គណនេយ្យ	ជារដ្ឋទេយ្យករបុរេប្រទាន
២-កញ្ញា **ប៊ុន ដាលីស**	ឋានៈជាអនុប្រធានការិយាល័យ ព័ត៌មានវិទ្យានិងសរុប	ជារដ្ឋទេយ្យករបុរេប្រទានរង

ប្រការ២._ បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះត្រូវទុកជានិរាករណ៍។

ប្រការ៣._ នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន ព្រមទាំងប្រធានអង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានភារកិច្ចទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៧

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

ចម ប្រសិទ្ធ

កន្លែងទទួល៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៦៩៥ សហវ.[illegible]

ប្រកាស
ស្តីពី
ប្រព័ន្ធកាមេរ៉ាត្រួតពិនិត្យគយ

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

ប្រការ ១.-

ប្រកាសនេះមានគោលបំណងដាក់ឱ្យអនុវត្តប្រព័ន្ធកាមេរ៉ាត្រួតពិនិត្យគយ ដើម្បីពង្រឹងប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការគ្រប់គ្រង ត្រួតពិនិត្យទំនិញនាំចេញ ទំនិញនាំចូល និងមធ្យោបាយដឹកជញ្ជូនដោយអនុលោមតាមច្បាប់ស្តីពីគយ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

ប្រការ ២.-

ប្រកាសនេះមានគោលដៅកំណត់នូវកិច្ចប្រតិបត្តិការប្រព័ន្ធកាមេរ៉ាសម្រាប់ឃ្លាំត្រួតពិនិត្យទំនិញនាំចេញ ទំនិញនាំចូល និងមធ្យោបាយដឹកជញ្ជូន នៅតាមបណ្តាការិយាល័យគយនិងរដ្ឋាករថ្នាក់មូលដ្ឋាន

និងបញ្ជូនព័ត៌មានមកថ្នាក់កណ្តាល ជាជំនួយក្នុងការផ្ទៀងផ្ទាត់ព័ត៌មានទំនិញ និងមធ្យោបាយដឹកជញ្ជូនឆ្លងកាត់ព្រំដែន ជាមួយនឹងព័ត៌មានទទួលបានពីប្រព័ន្ធគ្រប់គ្រងហានិភ័យគយ ប្រព័ន្ធព័ត៌មានសម្ងាត់គយ ប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ និងប្រព័ន្ធពាក់ព័ន្ធផ្សេងទៀត សំដៅជំរុញបន្ថែមនូវកិច្ចសម្រួលពាណិជ្ជកម្ម និងពង្រឹងអនុលោមភាពតាមច្បាប់ស្តីពីគយ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

ប្រការ ៣.-

ប្រកាសនេះមានវិសាលភាពតម្លើងនិងដាក់ឱ្យអនុវត្តប្រព័ន្ធកាមេរ៉ាត្រួតពិនិត្យគយនៅតាមបណ្តាការិយាល័យបំពេញបែបបទបញ្ចេញទំនិញពីគយ ដោយតភ្ជាប់មកប្រព័ន្ធមេ នៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ជាជំហានៗ តាមលទ្ធភាពធនធានហិរញ្ញវត្ថុ និងតាមតម្រូវការជាក់ស្តែង។

ប្រការ ៤.-

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាមានភារកិច្ច÷

- រៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធកាមេរ៉ាត្រួតពិនិត្យគយ
- បង្កើតអង្គភាពគ្រប់គ្រងប្រព័ន្ធកាមេរ៉ាត្រួតពិនិត្យគយ ដើម្បីសហការជាមួយដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ក្នុងការអនុវត្តគម្រោង និងកិច្ចដំណើរការប្រព័ន្ធ
- រៀបចំយន្តការគ្រប់គ្រង និងកសាងសេចក្តីណែនាំចាំបាច់នានាស្តីពីនីតិវិធី សំដៅធានាឱ្យមានតម្លាភាព និងប្រសិទ្ធភាពនៃការអនុវត្តតាមបញ្ញត្តិនៃប្រកាសនេះ
- រៀបចំផែនការសកម្មភាពកិច្ចប្រតិបត្តិការ ថែទាំ ជួសជុល និងកែលម្អប្រព័ន្ធ។

ប្រការ ៥.-

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាល អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិនា ឆ្នាំ២០១៧

អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល ÷

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.........សហវ.........

ប្រកាសអន្តរក្រសួង
ស្តីពី
ការបង្កើតរង្វាន់លើកទឹកចិត្តសម្រាប់ឆ្នាំ២០១៧ របស់ក្រសួងទេសចរណ៍

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

រដ្ឋមន្ត្រី
ក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៣៩ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដាឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នា២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ២០១៥ ស្ដីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រ៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ៤៨៨ អនុក្រ.បក ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៣ស្ដីពីការរៀបចំនិងការប្រព្រឹត្តិទៅ នៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៕
- បានឃើញអនុក្រឹត្យលេខ ៣៥អនក្រ.បកចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍ ៕
- បានឃើញប្រកាសអន្តរក្រសួងលេខ១៦២ អយក.ប្រក ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៥ ស្ដីពីការដាក់អោយអនុវត្តអង្គភាពថវិកា៕
- បានឃើញអនុក្រឹត្យលេខ៨២ អនុក្រ.ប្រក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ ៕
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.ប្រក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វាយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល ៕
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្ដីពីការអនុវត្តបទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ ៕
- បានឃើញប្រកាសលេខ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្ដីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ៕
- បានឃើញប្រកាសលេខ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្ដីពីការដាក់អោយអនុវត្តមាតិកាគណនី នៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ៕
- បានឃើញប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្ដីពីនីតិវិធីចំណាយរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ ៕
- ប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ស្ដីពីការកែសម្រួលប្រការ ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្ដីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ ៕
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងទេសចរណ៍

សម្រេច

ប្រការ ១-

ត្រូវបានបង្កើតរដ្ឋទេយ្យបុរេប្រទាន ជំពូក៦០ "ការទិញ" ជំពូក៦១ "សេវាកម្ម" នៅក្រសួងទេសចរណ៍ សម្រាប់មុខសញ្ញាចំណាយដូចមានចែងក្នុងប្រការ៥ថ្មី នៃប្រកាសលេខ៨២៩ សហវ.ប្រក ចុះ

ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

ប្រការ ២-

ចំនួនទឹកប្រាក់មួយជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន។

ប្រការ ៣-

បទបញ្ញាតិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

ប្រការ ៤-

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងទេសចរណ៍ត្រូវទទួលបន្ទុកអនុវត្ត ប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៧

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

រដ្ឋមន្ត្រី
ក្រសួងទេសចរណ៍

ថោង ខុន

កន្លែងទទួល
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមុខងារសាធារណៈ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយក រដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ ៤
-រាជកិច្ច
-ឯកសារ
-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍

ថវិកាកម្មវិធី

តារាងឧបសម្ព័ន្ធវេរទេយ្យបុរេប្រទានថវិកាកម្មវិធី របស់ក្រសួងទេសចរណ៍ សម្រាប់ឆ្នាំ២០១៧

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ	ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០១៧	ឥណទានដែលជ្រើសរើស	ឥណទាន វេរទេយ្យ បុរេប្រទាន	ឥណទាន ទូទាត់ធម្មតា	ឥណទាន ១ ជុំ បង្វិលវេរទេយ្យ បុរេប្រទាន	ភាគរយ
			1	2	3	4	5=3-4	6=4/4ជុំ	7=4/3
			សរុបរួម	30,688,000,000	18,473,600,000	9,228,244,400	9,245,355,600	2,307,061,100	50.0%
60			**ការទិញ**	2,828,500,000	1,492,100,000	564,100,000	928,000,000	141,025,000	37.8%
	6001		សំភារៈផ្គត់ផ្គង់ និងថែទាំ	683,000,000	159,000,000	159,000,000	-	39,750,000	100.0%
		60011	សំភារៈផ្គត់ផ្គង់ សំអាត និងអានាម័យ	93,000,000	93,000,000	93,000,000	-	23,250,000	100.0%
		60012	សំភារៈផ្គត់ផ្គង់ សម្រាប់ថែទាំអគារ និងប្រាសាទ	26,000,000	26,000,000	26,000,000	-	*6,500,000*	*100.0%*
		60014	សំភារៈផ្គត់ផ្គង់ថែទាំសំភារៈឧបករណ៍	40,000,000	40,000,000	40,000,000	-	*10,000,000*	*100.0%*
		60015	ប្រេងឥន្ធនៈ និងក្រេងរំអិល	524,000,000	-	-	-	-	*0.0%*
	6002		សំភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល	1,042,800,000	860,000,000	252,000,000	*608,000,000*	*63,000,000*	*29.3%*
		60021	សំភារៈការិយាល័យ និងការបោះពុម្ព	967,800,000	785,000,000	177,000,000	*608,000,000*	*44,250,000*	*22.5%*
		60022	សៀវភៅមើល និងឯកសារ	30,000,000	30,000,000	30,000,000	-	7,500,000	100.0%
		60028	ផ្សេងៗ	45,000,000	45,000,000	45,000,000	-	11,250,000	100.0%
	6004		សំលៀកបំពាក់ និងការតុបតែង	160,900,000	20,000,000	20,000,000	-	5,000,000	100.0%
		60041	ឯកសណ្ឋាន	140,900,000	-	-	-	-	*0.0%*
		60048	ផ្សេងៗ	20,000,000	20,000,000	20,000,000	-	5,000,000	100.0%
	6005		សំភារៈតូចតាច សង្ហារឹម និងសំភារៈបរិក្ខារ	553,100,000	453,100,000	133,100,000	*320,000,000*	33,275,000	29.4%

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ	ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០១៧	ឥណទានដែលជ្រើសរើស	ឥណទានរជ្ជទេយ្យបុរេប្រទាន	ឥណទានទូទាត់ធម្មតា	ឥណទាន ១ ជុំ បង្វិលរជ្ជទេយ្យបុរេប្រទាន	ភាគរយ
			1	2	3	4	5=3-4	6=4/4ជុំ	7=4/3
		60051	សំភារៈ និងបរិក្ខារបច្ចេកទេស	328,000,000	328,000,000	8,000,000	*320,000,000*	2,000,000	2.4%
		60052	សម្ភារឹម	100,000,000	-	-	-	-	*0.0%*
		60053	សំភារៈប្រើប្រាស់	70,100,000	70,100,000	70,100,000	-	17,525,000	100.0%
		60054	សំភារៈ និងឧបករណ៍ដឹកជញ្ជូន	30,000,000	30,000,000	30,000,000	-	7,500,000	100.0%
		60058	ផ្សេងៗ	25,000,000	25,000,000	25,000,000	-	6,250,000	100.0%
	6006		ថាមពល និងទឹក	388,700,000	-	-	-	-	*0.0%*
		60061	អគ្គិសនី	378,700,000	-	-	-	-	*0.0%*
		60062	ទឹក	10,000,000	-	-	-	-	*0.0%*
61			សេវាកម្ម	27,859,500,000	16,981,500,000	8,664,144,400	8,317,355,600	2,166,036,100	51.0%
	6102		ការជួលមធ្យោបាយដឹកជញ្ជូន	360,000,000	60,000,000	60,000,000	-	15,000,000	100.0%
	6104		សោហ៊ុយបណ្តុះបណ្តាលបុគ្គលិកក្នុង និងក្រៅប្រទេស	823,400,000	555,000,000	160,000,000	395,000,000	40,000,000	28.8%
	6105		ការថែទាំ និងជួសជុល	1,092,300,000	930,300,000	748,300,000	182,000,000	187,075,000	80.4%
		61052	ការថែទាំ ជួសជុលអគារ និងប្រាសាទ	340,200,000	340,200,000	241,200,000	99,000,000	60,300,000	70.9%
		61054	ការថែទាំបណ្តាញផ្សេងៗ	382,000,000	220,000,000	137,000,000	83,000,000	34,250,000	62.3%
		61056	ការថែទាំ និងជួសជុលមធ្យោបាយដឹកជញ្ជូន	200,100,000	200,100,000	200,100,000	-	50,025,000	100.0%
		61057	ការថែទាំ និងជួសជុលសំភារៈការិយាល័យ ព័ត៌មានវិទ្យា	112,000,000	112,000,000	112,000,000	-	28,000,000	100.0%
		61058	ការថែទាំ និងជួសជុលសំភារៈឧបករណ៍បច្ចេកទេស	58,000,000	58,000,000	58,000,000	-	14,500,000	100.0%
	6107		សោហ៊ុយសិក្សាពិសោធន៍ និងសោហ៊ុយនៃការប្រើប្រាស់សេវា	275,000,000	95,000,000	95,000,000	-	23,750,000	*100.0%*
		61071	សោហ៊ុយសិក្សាពិសោធន៍	275,000,000	95,000,000	95,000,000	-	23,750,000	*100.0%*
	6109		បុគ្គលិកខាងក្រៅ	174,000,000	-	-	-	-	*0.0%*
		61091	ភ្នាក់ងារជាតិជាប់កិច្ចសន្យា	12,000,000	-	-	-	-	*0.0%*

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ	ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០១៧	ឥណទានដែលត្រូវជ្រើសរើស	ឥណទាន រដ្ឋទេយ្យ បុរេប្រទាន	ឥណទាន ទូទាត់ធម្មតា	ឥណទាន ១ ជុំ បង្វិលរដ្ឋទេយ្យ បុរេប្រទាន	ភាគរយ
			1	2	3	4	5=3-4	6=4/4ជុំ	7=4/3
		61092	ភ្នាក់ងារបរទេសជាប់កិច្ចសន្យា	162,000,000	-	-	-	-	*0.0%*
	6110		ទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយ	17,456,200,000	12,126,100,000	4,472,100,000	7,654,000,000	1,118,025,000	36.9%
		61101	សោហ៊ុយទទួលភ្ញៀវជាតិ	517,000,000	517,000,000	517,000,000	-	129,250,000	100.0%
		61102	សោហ៊ុយទទួលភ្ញៀវបរទេស	1,044,000,000	1,044,000,000	662,000,000	382,000,000	165,500,000	63.4%
		61103	ប្រជុំ សិក្ខាសាលា និងសន្និសីទ	4,849,000,000	3,822,600,000	1,344,600,000	2,478,000,000	336,150,000	35.2%
		61104	សោហ៊ុយពិធីបុណ្យ	604,700,000	211,700,000	211,700,000	-	52,925,000	100.0%
		61105	ចំណាយសម្រាប់ទិញវត្ថុអនុស្សាវរីយ៍ក្នុង និងក្រៅប្រទេស	401,800,000	326,800,000	326,800,000	-	81,700,000	100.0%
		61106	សោហ៊ុយសម្រាប់ការតាំងពិព័រណ៍នៅក្នុង និងក្រៅប្រទេស	3,427,000,000	450,000,000	450,000,000	-	112,500,000	100.0%
		61107	ការឃោសនា និងផ្សព្វផ្សាយព័ត៌មានសាធារណៈ	6,272,700,000	5,754,000,000	960,000,000	4,794,000,000	240,000,000	16.7%
		61108	សោហ៊ុយទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយផ្សេងៗ	*340,000,000*	-	-	-	-	*0.0%*
	6111		សោហ៊ុយជាវសាព័ត៌មាន និងឯកសារ	108,000,000	108,000,000	108,000,000	-	27,000,000	100.0%
		61111	ចំណាយលើការជាវសារព័ត៌មាន	65,000,000	65,000,000	65,000,000	-	16,250,000	100.0%
		61112	ចំណាយលើការជាវទស្សនាវដ្ដី	30,000,000	30,000,000	30,000,000	-	7,500,000	*100.0%*
		61118	ចំណាយលើការជាវសារព័ត៌មាន និងឯកសារផ្សេងៗ	13,000,000	13,000,000	13,000,000	-	3,250,000	*100.0%*
	6112		ចំណាយទូទាត់សោហ៊ុយបេសកកម្មក្នុងប្រទេស	3,207,100,000	3,107,100,000	3,020,744,400	86,355,600	755,186,100	97.2%
		61121	សោហ៊ុយដឹកជញ្ជូន	916,100,000	880,600,000	855,516,400	25,083,600	213,879,100	97.2%
		61122	សោហ៊ុយបេសកកម្ម	486,700,000	477,200,000	468,208,000	8,992,000	117,052,000	98.1%
		61123	សោហ៊ុយស្នាក់នៅ និងហូបចុក	1,804,300,000	1,749,300,000	1,697,020,000	52,280,000	424,255,000	97.0%
	6113		ចំណាយទូទាត់សោហ៊ុយបេសកកម្មក្រៅប្រទេស	*4,298,500,000*	-	-	-	-	0.0%
		61131	សោហ៊ុយដឹកជញ្ជូន	*1,765,600,000*	-	-	-	-	0.0%
		61132	សោហ៊ុយបេសកកម្ម	*337,700,000*	-	-	-	-	0.0%

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ	ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០១៧	ឥណទានដែលជ្រើសរើស	ឥណទាន វជ្ជទេយ្យ បុរេប្រទាន	ឥណទាន ទូទាត់ជម្រះ	ឥណទាន ១ ជុំ បង្វិលវជ្ជទេយ្យ បុរេប្រទាន	ភាគរយ
			1	2	3	4	5=3-4	6=4/4ជុំ	7=4/3
		61133	សោហ៊ុយស្នាក់នៅ និងហូបចុក	2,195,200,000	-	-	-	-	0.0%
	6114		សោហ៊ុយប្រេណីយ៍ និងទូរគមនាគមន៍	65,000,000	-	-	-	-	0.0%
		41142	សោហ៊ុយទូរគមនាគមន៍	65,000,000	-	-	-	-	0.0%

បានឃើញ និងពិនិត្យត្រឹមត្រូវ
ភ្នំពេញ ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០១៧
ស. អគ្គនាយក
អគ្គនាយកដ្ឋានរតនាគារជាតិ
អគ្គនាយករង
និញ្ញ បានសុវណ្ណអាន់និច្ចសីលា

បានឃើញ និងពិនិត្យត្រឹមត្រូវ
ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៧
អគ្គនាយក
អគ្គនាយកដ្ឋានថវិកា
ម៉េង_វណ្ណា

បានឃើញ និងពិនិត្យត្រឹមត្រូវ
ភ្នំពេញ ថ្ងៃទី ២០ ខែ ០២ ឆ្នាំ២០១៧
ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ
អៀ វុត្ថារា

ភ្នំពេញ ថ្ងៃទី ២០ ខែ ០២ ឆ្នាំ២០១៧
វជ្ជទេយ្យករបុរេប្រទាន
អ៊ុក សាក់សំបែ

បានឃើញ និងឯកភាព
ភ្នំពេញ ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ២០១៧
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

បានឃើញ និងឯកភាព
ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៧
រដ្ឋមន្ត្រីក្រសួងទេសចរណ៍
ថោង ខុន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ [illegible] សហវ.ប្រក

រាជធានីភ្នំពេញ,ថ្ងៃទី០៩ ខែ[illegible] ឆ្នាំ២០១៧

ប្រកាស
ស្តីពី
ការតែងតាំងគណៈនេយ្យករ
នៅសាលាជាតិកសិកម្មព្រែកលៀប

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/៩៤ ចុះថ្ងៃទី ២១ ខែ មិនា ឆ្នាំ ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្ម មាត្រ ០៩ និងមាត្រា ១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តិ នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ២០១៥ ស្តីពីការកែសម្រួលមាត្រ ៤៤ មាត្រា ៤៥ មាត្រា ៤៦ និងមាត្រា ៤៧ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការបង្កើតសាលាជាតិកសិកម្មព្រែកលៀបជាគ្រឹះស្ថានសាធារណរដ្ឋបាល
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនី នៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១៣៩ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិរដ្ឋ នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកា នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៣៩៦ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៦ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមតម្រូវការចាំបាច់ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (សាលាជាតិកសិកម្មព្រែកលៀប)

សម្រេច

ប្រការ១-

ត្រូវបានតែងតាំងលោក **សិត ទិសិដ្ឋ** ជាគណនេយ្យករ នៅសាលាជាតិកសិកម្មព្រែកលៀប។

ប្រការ២-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៣-

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយក គ្រប់អគ្គនាយកដ្ឋាន ប្រធាននាយកដ្ឋាន នាយកសាលាជាតិកសិកម្មព្រែកលៀប និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល

- ទីស្តីការ គណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតី តេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ២៦២ សហវ.ប្រក

ប្រកាសរួម
ស្តីពី
ការពិន័យអន្តរការណ៍ជាប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីទេសចរណ៍

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

រដ្ឋមន្ត្រី ក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្ដីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសរួមលេខ ៩៩៧ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្ដីពីការផ្ដល់សេវាសាធារណៈរបស់ក្រសួងទេសចរណ៍
- យោងតាមការចាំបាច់របស់ក្រសួងទេសចរណ៍ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

ប្រការ១ .-

អនុញ្ញាតឱ្យក្រសួងទេសចរណ៍ អនុវត្តការប្រមូលចំណូលពីការពិន័យអន្តរការណ៍ជាប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្ដីពីទេសចរណ៍ ដើម្បីជាគុណប្រយោជន៍ដល់ថវិកាជាតិ។

ប្រការ២ .-

កម្រិតទឹកប្រាក់នៃការពិន័យអន្តរការណ៍ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្ដីពីទេសចរណ៍ ត្រូវបានកំណត់ផ្អែកទៅតាមស្ថានទម្ងន់នៃអំពើល្មើសលើប្រភេទបទល្មើសនីមួយៗ ដែលមានចែងលម្អិតនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមនេះ។

ប្រការ៣ .-

ក្នុងករណីដែលអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្ដីពីទេសចរណ៍ មិនបានបង់ប្រាក់ពិន័យអន្តរការណ៍ ឬ មិនបានដាក់ពាក្យប្តឹងតវ៉ា ក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃដែលទទួលបានលិខិតអញ្ជើញឱ្យបង់ប្រាក់ពិន័យ នោះចំនួនទឹកប្រាក់ពិន័យអន្តរការណ៍នឹងត្រូវដំឡើងជាពីរដង នៃកម្រិតទឹកប្រាក់ពិន័យអន្តរការណ៍ដែលបានកំណត់នៅក្នុងប្រការ២ នៃប្រកាសរួមនេះ។

ករណីក្នុងរយៈពេល ៩០(កៅសិប) ថ្ងៃ គិតចាប់ពីថ្ងៃដែលទទួលបានលិខិតអញ្ជើញឱ្យបង់ប្រាក់ពិន័យ ហើយអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្ដីពីទេសចរណ៍ នៅតែមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ មន្ត្រីជំនាញនៃក្រសួងទេសចរណ៍ត្រូវរៀបចំសំណុំឯកសារប្តឹងទៅសាលាជម្រះក្តី ដើម្បីចាត់ការទៅតាមច្បាប់ជាធរមាន ក្នុងការផ្តន្ទាទោសពិន័យជាប្រាក់ និងការដាក់ទោសទណ្ឌផ្សេងៗទៀត ដែលសម្រេចដោយសាលាជម្រះក្តី។

ប្រការ៤ .-

ក្រសួងទេសចរណ៍ ត្រូវផ្សព្វផ្សាយជាសាធារណៈនូវប្រកាសរួម និងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមនេះ។

ប្រការ៥ .-

នីតិវិធី និងលក្ខខណ្ឌនៃការពិន័យអន្តរការណ៍ជាប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីទេសចរណ៍ ដែលមានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសរួមនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

ប្រការ៦ .-

ការបែងចែកភារកិច្ចលើការគ្រប់គ្រង និងការប្រមូលចំណូលពីការពិន័យអន្តរការណ៍ជាប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីទេសចរណ៍ រវាងរដ្ឋបាលកណ្តាលក្រសួងទេសចរណ៍ និងមន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។ ក្រសួងទេសចរណ៍ ត្រូវផ្ញើប្រកាសនេះចំនួនមួយច្បាប់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជូនជ្រាបជាព័ត៌មាន និងសម្រាប់តាមដានការអនុវត្តចំណូល។

ប្រការ៧ .-

រាល់ការប្រមូល ឬ ការទទួលប្រាក់ចំណូលដោយផ្ទាល់ជាសាច់ប្រាក់ ឬ ជាមូលប្បទានប័ត្រ លើការពិន័យអន្តរការណ៍ជាប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីទេសចរណ៍ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ដែលបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ ដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ប្រការ៨ .-

រដ្ឋបាលកណ្តាលក្រសួងទេសចរណ៍ និងមន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវទទួលខុសត្រូវប្រាក់កាសលើប្រាក់ចំណូលប្រមូលបាន, បង់ប្រាក់ចំណូល និងធ្វើសលាកប័ត្រចំណូលថវិកាជាតិ ព្រមទាំងចុះកិច្ចបញ្ជិកាគណនេយ្យស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាចំណូលថវិកា។

ប្រការ៩ .-

ក្រសួងទេសចរណ៍ ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

មន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ផ្ញើជូនក្រសួងទេសចរណ៍ និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

របាយការណ៍ស្តីពីការអនុវត្តចំណូលខាងលើនេះ ជាផ្នែកមួយនៃរបាយការណ៍រួមស្តីពីការអនុវត្តចំណូលរបស់រដ្ឋបាលកណ្តាលក្រសួងទេសចរណ៍ និងមន្ទីរទេសចរណ៍រាជធានី ខេត្ត។

ប្រការ១០ .-

កម្រិតទឹកប្រាក់នៃការពិន័យអន្តរការណ៍ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីទេសចរណ៍ អាចកែប្រែបានតាមការចាំបាច់ ដែលកំណត់ដោយប្រកាសរួម រវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

ប្រការ១១ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

ប្រការ១២ .-

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងទេសចរណ៍ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៧ តទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០១៧

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

រដ្ឋមន្ត្រី
ក្រសួងទេសចរណ៍

ថោង ខុន

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត
- ដូចប្រការ១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

តារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ..៩៦២... សហវ.ប្រក ចុះថ្ងៃទី..២០.... ខែ..មីនា.. ឆ្នាំ២០១៧

ការពិន័យអន្តរការណ៍ជាប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីទេសចរណ៍

ល.រ	បរិយាយ	នីតិប្រាក់ពិន័យអន្តរការណ៍ (រៀល)	
		គ្មានអាជ្ញាប័ណ្ណ	អាជ្ញាប័ណ្ណហួសសុពលភាព
ក. ប្រភេទបទល្មើសទូទៅ			
១	ការផ្សព្វផ្សាយព័ត៌មានមិនពិតពាក់ព័ន្ធនឹងការធ្វើអាជីវកម្មលើវិស័យទេសចរណ៍	៣០០ ០០០	
២	គ្មានបញ្ជីតារាងដែលបញ្ជាក់ពីតម្លៃសេវាកម្ម ឬ មុខម្ហូបអាហារភេសជ្ជៈនីមួយៗ	៣៥០ ០០០	
៣	ការផ្លាស់ប្តូរទីតាំងដែលមិនបានជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងទេសចរណ៍ ក្នុងអំឡុងរយៈពេលសុពលភាពនៃអាជ្ញាប័ណ្ណ	៦០០ ០០០	
៤	ការមិនសហការប្តឹង ឬ រាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរមានសមត្ថកិច្ចពីសកម្មភាពរបស់ភ្ញៀវទេសចរណ៍ ឬ សកម្មភាពផ្សេងដែលកើតមកលើភ្ញៀវទេសចរនូវសកម្មភាព ដែលច្បាប់បានហាមឃាត់	១ ០០០ ០០០	
៥	ការធ្វើកិច្ចព្រមព្រៀងជាមួយរូបវន្តបុគ្គល ឬ នីតិបុគ្គលដែលឋិតនៅក្រោមសមត្ថកិច្ចក្រសួងទេសចរណ៍ ដោយគ្មានអាជ្ញាប័ណ្ណទេសចរណ៍	១ ០០០ ០០០	
៦	ការរារាំងដល់មន្ត្រីមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យសកម្មភាពអាជីវកម្ម	១ ០០០ ០០០	
ខ. ប្រភេទបទល្មើសដោយឡែក			
៧	ខ១- អាជីវកម្មទីភ្នាក់ងារទេសចរណ៍ (ការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍)	២ ០០០ ០០០	២ ០០០ ០០០
	ខ២- អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅ		
	ខ២.១- សណ្ឋាគារ ឬ សណ្ឋាគារអាផាតមិន ឬ សណ្ឋាគារស្វីត ឬ សណ្ឋាគាររីសត ឬ ប៊ីងហ្គាឡូ ឬ ម៉ូតែល ឬ ឡូដ៍ (Lodge)		
៨	- ចំណុះត្រឹម ១០០ បន្ទប់	២ ០០០ ០០០	២ ០០០ ០០០
៩	- ចំណុះពី ១០១ បន្ទប់ ដល់ ១៥០ បន្ទប់	៣ ០០០ ០០០	២ ០០០ ០០០
១០	- ចំណុះពី ១៥១ បន្ទប់ ដល់ ២០០ បន្ទប់	៣ ៩០០ ០០០	២ ៦០០ ០០០
១១	- ចំណុះពី ២០១ បន្ទប់ ដល់ ៣០០ បន្ទប់	៤ ៩៥០ ០០០	៣ ៣០០ ០០០
១២	- ចំណុះពី ៣០១ បន្ទប់ ឡើងទៅ	៦ ០០០ ០០០	៤ ០០០ ០០០
	ខ២.២- ផ្ទះភ្ញៀវ		
១៣	- ចំណុះត្រឹម ៥០ បន្ទប់	២ ០០០ ០០០	២ ០០០ ០០០
១៤	- ចំណុះពី ៥១ បន្ទប់ ដល់ ១០០ បន្ទប់	២ ២៥០ ០០០	២ ០០០ ០០០
១៥	- ចំណុះពី ១០១ បន្ទប់ ដល់ ឡើងទៅ	៤ ៥០០ ០០០	៣ ០០០ ០០០
១៦	ខ២.៣- កន្លែងបោះជំរំ	២ ០០០ ០០០	២ ០០០ ០០០
	ខ៣- អាជីវកម្មភោជនីយដ្ឋាន អាហារដ្ឋាន		
១៧	- ចំណុះត្រឹម ៣០០ នាក់	២ ០០០ ០០០	២ ០០០ ០០០
១៨	- ចំណុះពី ៣០១ នាក់ឡើងទៅ	២ ៥០០ ០០០	២ ០០០ ០០០

ល.រ	បរិយាយ	ទឹកប្រាក់ពិន័យអន្តរការណ៍ (រៀល)	
		គ្មានអាជ្ញាប័ណ្ណ	អាជ្ញាប័ណ្ណហួសសុពលភាព
	១៤- អាជីវកម្មបៀរហ្គាឌិន ខារ៉ាអូខេ ម៉ាស្សាសុខភាព-ស្ប៉ា និងរង្គសាលឌីស្កូតែក		
	១៤.១- បទល្មើសពាក់ព័ន្ធនឹងការធ្វើសកម្មភាព		
១៩	- មិនមានបញ្ជីឈ្មោះប្រភេទនៃសេវាកម្មដោយបញ្ជាក់ពីតម្លៃនីមួយៗដល់ភ្ញៀវ	៥០០ ០០០	
២០	- អនុញ្ញាតឱ្យនីតិជនចូលក្នុងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ	១ ៥០០ ០០០	
	១៤.២- ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាប័ណ្ណ ឬ អាជ្ញាប័ណ្ណហួសសុពលភាព		
	១៤.២.១- បៀរហ្គាឌិន		
២១	- ចំណុះត្រឹម ៣០០ នាក់	២ ០០០ ០០០	២ ០០០ ០០០
២២	- ចំណុះពី ៣០១ នាក់ឡើងទៅ	៣ ០០០ ០០០	២ ០០០ ០០០
	១៤.២.២- ខារ៉ាអូខេ		
២៣	- ចំណុះត្រឹម ១០ បន្ទប់	២ ០០០ ០០០	២ ០០០ ០០០
២៤	- ចំណុះពី ១១ បន្ទប់ ដល់ ២០ បន្ទប់	២ ៤០០ ០០០	២ ០០០ ០០០
២៥	- ចំណុះពី ២១ បន្ទប់ ដល់ ៤០ បន្ទប់	៤ ៥០០ ០០០	៣ ០០០ ០០០
២៦	- ចំណុះពី ៤១ បន្ទប់ ឡើងទៅ	៦ ០០០ ០០០	៤ ០០០ ០០០
២៧	១៤.២.៣- ម៉ាស្សាសុខភាព និងស្ប៉ា	២ ០០០ ០០០	២ ០០០ ០០០
	១៤.២.៥- រង្គសាលឌីស្កូតែក ឬ រង្គសាល-ឌីស្កូតែក		
២៨	- ចំណុះត្រឹម ១០០ នាក់	២ ០០០ ០០០	២ ០០០ ០០០
២៩	- ចំណុះពី ១០១ នាក់ ដល់ ១៥០ នាក់	៣ ០០០ ០០០	២ ០០០ ០០០
៣០	- ចំណុះពី ១៥១ នាក់ ដល់ ២០០ នាក់	៦ ០០០ ០០០	៤ ០០០ ០០០
៣១	- ចំណុះពី ២០១ នាក់ ឡើងទៅ	៩ ០០០ ០០០	៦ ០០០ ០០០
	១៥- អាជីវកម្មដឹកជញ្ជូនភ្ញៀវទេសចរតាមផ្លូវទឹក និងផ្លូវគោក		
	១៥.១- បទល្មើសពាក់ព័ន្ធនឹងការធ្វើសកម្មភាព		
៣២	- សេវាដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹកអត់ពោងសុវត្ថិភាព	១០០ ០០០	
៣៣	- ការដាក់ភ្ញៀវលើសចំណុះ	២០០ ០០០	
៣៤	- ការបោះបង់ចោលភ្ញៀវនៅពេលដែលបំពេញការងាររបស់ខ្លួន	៥០០ ០០០	
៣៥	១៥.២- ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាប័ណ្ណ ឬ អាជ្ញាប័ណ្ណហួសសុពលភាព	២ ០០០ ០០០	២ ០០០ ០០០
	១៦- អាជីវកម្មកីឡាទេសចរណ៍		
៣៦	១៦.១- កីឡាស្គកយ័រ, ម៉ាស៊ីនហ្គេម, ក្លឹបកំសាន្តប៊ូលីង	២ ០០០ ០០០	២ ០០០ ០០០
	១៦.៤- ក្លឹបហ្វឹកហាត់វាយកូនគោល		
៣៧	- ចំណុះត្រឹម ១០ កន្លែង	២ ០០០ ០០០	២ ០០០ ០០០
៣៨	- ចំណុះពី ១០ ដល់ ៥០ កន្លែង	៣ ០០០ ០០០	២ ០០០ ០០០
៣៩	- ចំណុះពី ៥១ កន្លែង ឡើងទៅ	៦ ០០០ ០០០	៤ ០០០ ០០០

ល.រ	បរិយាយ	និក្ខេបពិន័យអន្តរការណ៍ (រៀល)	
		គ្មានអាជ្ញាប័ណ្ណ	អាជ្ញាប័ណ្ណហួសសុពលភាព
	១៦.៥- ក្លឹបកីឡាវាយកូនគោល		
៥០	- ចំណុះត្រឹម ០៩ រន្ធ	៦ ០០០ ០០០	៤ ០០០ ០០០
៥១	- ចំណុះពី ១៨ រន្ធ ឡើងទៅ	១២ ០០០ ០០០	៨ ០០០ ០០០
	១៦.៦- កីឡាទេសចរណ៍ផ្សេងៗទៀត		
៤៥	- កីឡាប្រណាំងឡាន, កីឡាបាញ់ព្រួញ និងកាំភ្លើងគ្រាប់មិនពិត, កីឡាសៀក, កីឡាជិះកង់រង្វង់, កីឡាជិះដីរ៉ា, កីឡាជិះសេះ, រថយន្ត ឬ រថភ្លើងអគ្គសនី, កីឡាស្គីលើទឹក, ក្តារបណ្តែត, ហែលទឹកមុជទឹក, បាល់ឡុងបង្ហោះ, រថយន្តខ្សែកាប	២ ០០០ ០០០	២ ០០០ ០០០
៤៦	- យន្តហោះ ឬ ឧទ្ធម្ភាចក្រជិះកំសាន្ត	៣ ០០០ ០០០	២ ០០០ ០០០
	១៧- អាជីវកម្មរមណីយដ្ឋានទេសចរណ៍		
៤៧	- រមណីយដ្ឋានថ្នាក់ជាតិ	១៥ ០០០ ០០០	១០ ០០០ ០០០
៤៨	- រមណីយដ្ឋានថ្នាក់ខេត្ត	៧ ៥០០ ០០០	៥ ០០០ ០០០
៤៩	- រមណីយដ្ឋានថ្នាក់ស្រុក	៤ ៥០០ ០០០	៣ ០០០ ០០០
៥០	- រមណីយដ្ឋានថ្នាក់កែច្នៃ	៣ ០០០ ០០០	២ ០០០ ០០០
	១៨- អាជីវកម្មមគ្គុទ្ទេសក៍ទេសចរណ៍		
	១៨.១-បទល្មើសពាក់ព័ន្ធនឹងការធ្វើសកម្មភាព		
៥១	- មគ្គុទ្ទេសក៍ទេសចរណ៍មិនពាក់ឯកសណ្ឋាន ឬ សញ្ញាសម្គាល់ដែលចេញដោយក្រសួងទេសចរណ៍ ឬ មន្ទីរទេសចរណ៍	២០ ០០០	
៥២	- ការនាំភ្ញៀវចូលទៅកន្លែងដែលអាជ្ញាធរបានហាមឃាត់	៥០ ០០០	
៥៣	- ការផ្តល់ព័ត៌មានមិនពិតក្នុងវិស័យទេសចរណ៍ដល់ភ្ញៀវទេសចរ	៥០ ០០០	
៥៤	- ការមិនគោរពទៅតាមក្រមប្រតិបត្តិវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍	៥០ ០០០	
៥៥	- ការពិសាគ្រឿងស្រវឹងក្នុងពេលបំពេញការងារ	៦០ ០០០	
	១៨.២- ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាប័ណ្ណ ឬ អាជ្ញាប័ណ្ណហួសសុពលភាព		
៥៦	- ថ្នាក់សហគមន៍	២ ០០០ ០០០	២ ០០០ ០០០
៥៧	- ថ្នាក់ក្រោមជាតិ	២ ០០០ ០០០	២ ០០០ ០០០
៥៨	- ថ្នាក់តំបន់	២ ០០០ ០០០	២ ០០០ ០០០
៥៩	- ថ្នាក់ជាតិ	២ ០០០ ០០០	២ ០០០ ០០០
៦០	- ថ្នាក់ពិសេស	២ ០០០ ០០០	២ ០០០ ០០០
	១៩- ចំណាត់ថ្នាក់សណ្ឋាគារ ឬ សេវាកម្មស្នាក់នៅទេសចរណ៍		
៦១	- ចំណាត់ថ្នាក់ក្រោមផ្កាយ	២ ០០០ ០០០	២ ០០០ ០០០
៦២	- ចំណាត់ថ្នាក់ផ្កាយ ១	២ ០០០ ០០០	២ ០០០ ០០០

ល.រ	បរិយាយ	ទឹកប្រាក់ពិន័យអន្តរការណ៍ (រៀល)	
		គ្មានអាជ្ញាប័ណ្ណ	អាជ្ញាប័ណ្ណហួសសុពលភាព
៦៣	- ចំណាត់ថ្នាក់ផ្កាយ ២	២ ០០០ ០០០	២ ០០០ ០០០
៦៤	- ចំណាត់ថ្នាក់ផ្កាយ ៣	៣ ០០០ ០០០	២ ០០០ ០០០
៦៥	- ចំណាត់ថ្នាក់ផ្កាយ ៤	៤ ៥០០ ០០០	៣ ០០០ ០០០
៦៦	- ចំណាត់ថ្នាក់ផ្កាយ ៥	៦ ០០០ ០០០	៤ ០០០ ០០០
	១១០- ស្តង់ដារអប្បរមារមណីយដ្ឋានទេសចរណ៍		
៦៧	- គុណភាពមធ្យម (C)	២ ០០០ ០០០	២ ០០០ ០០០
៦៨	- គុណភាពមធ្យម (B)	២ ២៥០ ០០០	២ ០០០ ០០០
៦៩	- គុណភាពមធ្យម (A)	៣ ០០០ ០០០	២ ០០០ ០០០
	១១១- អ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍		
៧០	- ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាប័ណ្ណ ឬ អាជ្ញាប័ណ្ណហួសសុពលភាព	២ ០០០ ០០០	២ ០០០ ០០០

<u>កំណត់សម្គាល់ ÷</u>

- ការពិន័យអន្តរការណ៍ជាប្រាក់ដែលអនុវត្តដោយក្រសួងទេសចរណ៍ ត្រូវបានកំណត់ទឹកប្រាក់ពិន័យអតិបរមាត្រឹម ២០លានរៀល។
- ការបង់ប្រាក់ពិន័យអន្តរការណ៍ ត្រូវបានចាត់ទុកថាជាករណីដោយឡែកសម្រាប់ការដោះបន្ទុកលើប្រភេទបទល្មើស ដែលសាមីជនបានប្រព្រឹត្តតែប៉ុណ្ណោះ។ ចំពោះការស្នើសុំអាជ្ញាប័ណ្ណទេសចរណ៍ថ្មី ឬ បន្តអាជ្ញាប័ណ្ណទេសចរណ៍ តម្រូវឱ្យម្ចាស់សេវាកម្ម ឬ ម្ចាស់អាជីវកម្ម ត្រូវបង់ថ្លៃអាជ្ញាប័ណ្ណទេសចរណ៍ ទៅតាមតម្លៃដែលបានកំណត់ដោយប្រកាសរួមរបស់ក្រសួងទេសចរណ៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ក្នុងករណីដែលអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីទេសចរណ៍ មិនបានបង់ប្រាក់ពិន័យអន្តរការណ៍ ឬ មិនបានដាក់ពាក្យប្តឹងតវ៉ា ក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃដែលទទួលបានលិខិតអញ្ជើញឱ្យបង់ប្រាក់ពិន័យ នោះចំនួនទឹកប្រាក់ពិន័យអន្តរការណ៍នឹងត្រូវដំឡើងជាពីរដង នៃកម្រិតទឹកប្រាក់ពិន័យអន្តរការណ៍ដែលបានកំណត់នៅក្នុងតារាងឧបសម្ព័ន្ធនេះ។ ករណីមិនបានបង់ប្រាក់ពិន័យក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ គិតចាប់ពីថ្ងៃដែលទទួលបានលិខិតអញ្ជើញឱ្យបង់ប្រាក់ពិន័យ នោះមន្ត្រីជំនាញនៃក្រសួងទេសចរណ៍ត្រូវរៀបចំសំណុំឯកសារប្តឹងទៅសាលាជម្រះក្តី ដើម្បីដោះស្រាយទៅតាមនីតិវិធីតុលាការ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ២២៣ សហវ.ក.ប្រក

ប្រកាសរួម
ស្ដីពី
ការផ្ដល់ថវិកាលើកទឹកចិត្តលើការគ្រប់គ្រង និងការប្រមូលចំណូលពីការពិន័យអន្តរការណ៍ ជាប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្ដីពីទេសចរណ៍

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

រដ្ឋមន្ត្រី
ក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសរួមលេខ ៩៩៨ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងទេសចរណ៍ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសរួមលេខ ១០០២ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងយុត្តិធម៌ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសរួមលេខ...២៦២.... សហវ.ប្រក ចុះថ្ងៃទី..១០.... ខែ..[illegible].... ឆ្នាំ២០១៧ ស្តីពីការពិន័យអន្តរការណ៍ជាប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីទេសចរណ៍
- យោងតាមការចាំបាច់របស់ក្រសួងទេសចរណ៍ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

ប្រការ១ .–

ត្រូវបានផ្តល់ថវិការង្វាន់លើកទឹកចិត្តជូនក្រសួងទេសចរណ៍, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសាលាជម្រះក្តីពាក់ព័ន្ធ សម្រាប់ឧបត្ថម្ភជូនមន្ត្រីដែលបំពេញភារកិច្ចផ្ទាល់ និងមន្ត្រីផ្សេងៗទៀត ព្រមទាំងសម្រាប់ពង្រឹងយន្តការប្រមូលចំណូល លើការគ្រប់គ្រង និងការប្រមូលចំណូលពីការពិន័យអន្តរការណ៍ជាប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីទេសចរណ៍។

ប្រការ២ .–

ការផ្តល់ថវិការង្វាន់លើកទឹកចិត្ត ត្រូវបានបែងចែកដាច់ដោយឡែកពីគ្នារវាងរដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួងទេសចរណ៍ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋានប្រាក់ចំណូលប្រមូលបានពីការពិន័យអន្តរការណ៍ជាប្រាក់រវាងរដ្ឋបាលកណ្តាលក្រសួងទេសចរណ៍ និងមន្ទីរទេសចរណ៍រាជធានី ខេត្ត។

ប្រការ៣ .–

ចំណូលប្រមូលបានពីការពិន័យជាប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីទេសចរណ៍ ត្រូវបានបែងចែកដូចតទៅ ÷

១-ចំណូលប្រមូលបានពីការពិន័យអន្តរការណ៍ជាប្រាក់ ត្រូវបានបែងចែកដូចខាងក្រោម ÷

- បង់ចូលថវិកាជាតិចំនួន ៥០% នៃប្រាក់ពិន័យដែលប្រមូលបាន
- ផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងទេសចរណ៍ចំនួន ៤៩% នៃប្រាក់ពិន័យដែលប្រមូលបាន
- ផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន ១% នៃប្រាក់ពិន័យដែលប្រមូលបាន។

២-ករណីចំណូលប្រមូលបានពីការផ្តន្ទាទោសពិន័យជាប្រាក់ដែលអនុវត្តតាមការសម្រេចរបស់សាលាជម្រះក្តី ត្រូវបានបែងចែកដូចខាងក្រោម ÷

- បង់ចូលថវិកាជាតិចំនួន ២៦% នៃប្រាក់ពិន័យដែលប្រមូលបាន
- ផ្តល់រង្វាន់លើកទឹកចិត្តសរុបជូនសាលាជម្រះក្តីពាក់ព័ន្ធចំនួន ២៤% នៃប្រាក់ពិន័យដែលប្រមូលបាន ស្របតាមប្រកាសរួមលេខ ១០០២ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងយុត្តិធម៌ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងទេសចរណ៍ចំនួន ៤៩% នៃប្រាក់ពិន័យដែលប្រមូលបាន
- ផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន ១% នៃប្រាក់ពិន័យដែលប្រមូលបាន។

ប្រការ៤ .-

អនុញ្ញាតឱ្យរដ្ឋបាលកណ្តាលក្រសួងទេសចរណ៍ និងមន្ទីរទេសចរណ៍រាជធានី ខេត្ត បុរេប្រទានប្រាក់រង្វាន់លើកទឹកចិត្តសរុបពីប្រាក់ចំណូលដែលប្រមូលបានរៀងៗខ្លួន ពីការពិន័យអន្តរការណ៍ជាប្រាក់ ដែលអនុវត្តតាមប្រកាសរួមលេខ ២៦២... សហវ.ប្រក ចុះថ្ងៃទី..២០... ខែ..មីនា... ឆ្នាំ២០១៧ ស្តីពីការពិន័យអន្តរការណ៍ជាប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីទេសចរណ៍ ដើម្បីចាត់ចែងបើកផ្តល់ជូនដល់អង្គភាពគោលដៅដែលមានការពាក់ព័ន្ធ។

ប្រការ៥ .-

រដ្ឋបាលកណ្តាលក្រសួងទេសចរណ៍ និងមន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវគ្រោងចំណូលសរុប និងចំណាយសម្រាប់ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត នៅក្នុងគម្រោងចំណូល និងចំណាយនៃថវិកាប្រចាំឆ្នាំរបស់ខ្លួនដោយឡែកពីគ្នា។ រដ្ឋបាលកណ្តាលក្រសួងទេសចរណ៍ ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ការចំណាយលើប្រាក់រង្វាន់របស់រដ្ឋបាលកណ្តាលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងប្រាក់រង្វាន់របស់សាលាជម្រះក្តី។ មន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ការចំណាយលើប្រាក់រង្វាន់របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត និងប្រាក់រង្វាន់របស់សាលាជម្រះក្តី។ ឥណទានដែលបានគ្រោងសម្រាប់ការចំណាយលើប្រាក់រង្វាន់ ជាកម្មវត្ថុនៃការធ្វើអាណត្តិបើកប្រាក់(អាណត្តិនិយ័តកម្ម) ដើម្បីទូទាត់ជាមួយចំនួនទឹកប្រាក់ដែលបានបុរេប្រទានពីចំណូលថវិកាជាតិ។

រាល់ប្រតិបត្តិការនៃចំណូល និងចំណាយទាំងនេះ ត្រូវកត់ត្រាឆ្លុះបញ្ចាំងក្នុងថវិកាជាតិ ដូចកិច្ចប្រតិបត្តិការនៃចំណូល និងចំណាយដទៃទៀតរបស់រដ្ឋបាលកណ្តាល និងមន្ទីរទេសចរណ៍រាជធានី ខេត្ត នៃក្រសួងទេសចរណ៍ ដែរ។

ប្រការ៦ .-

ការគណនា ការបុរេប្រទាន ការប្រើប្រាស់ និងការទូទាត់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវអនុលោមតាមការកំណត់នៃសារាចរណែនាំលេខ ០០១ សហវ.ចមព ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីគោលការណ៍ និងនីតិវិធីផ្តល់រង្វាន់លើកទឹកចិត្តលើការផ្តល់សេវាសាធារណៈ។

ប្រការ៧ .-

ការបើកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវអនុវត្តដូចខាងក្រោម ÷

ក. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងទេសចរណ៍ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ដោយឈរលើគោលការណ៍សមធមិ និងផ្អែកតាមគុណសម្បត្តិការងារ។

ខ. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយឈរលើគោលការណ៍សមធមិ និងផ្អែកតាមគុណសម្បត្តិការងារ។

គ. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃសាលាជម្រះក្តីពាក់ព័ន្ធ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធមិ ដោយឈរលើគោលការណ៍សមធមិ និងផ្អែកតាមគុណសម្បត្តិការងារ។

ប្រការ៨ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៩ .-

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងទេសចរណ៍ និងក្រសួងយុត្តិធមិ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៧ តទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០១៧

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

រដ្ឋមន្ត្រី
ក្រសួងទេសចរណ៍
ថោង ខុន

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ០៩៤ ឧស.ក.ស.ក.ស.០៣

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០១៧

ប្រកាសបង្កើតរោងចក្រ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្តូរប្រកាសបង្កើតរោងចក្រ ផលិតគ្រឿងបង្គុំអេឡិចត្រូនិច ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧ របស់ក្រុមហ៊ុន អេសតិច ខបភើរេសិន (ខេមបូឌា)។

សម្រេច

ប្រការ១៖ អនុញ្ញាតឱ្យក្រុមហ៊ុន អេសតិច ខបភើរេសិន (ខេមបូឌា) (ESTec Corporation (Cambodia) LTD.) តំណាងដោយ លោក LEE SUK JEONG បង្កើតរោងចក្រ **ផលិតគ្រឿងបង្គុំអេឡិចត្រូនិច** ដែលមានទីតាំងស្ថិតនៅ ភូមិព្រៃព្រីងខាងត្បូង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

ឈ្មោះផលិតផល	**លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code**
១-ឧបករណ៍ស្តាប់សម្លេងភ្ជាប់ត្រចៀក (Headphone)	២៦៤០
២-ឧបករណ៍បំពងសម្លេង (Speaker)	២៦៤០

ប្រការ២៖ ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ផ្លាកឈ្មោះរោងចក្រ៖"រោងចក្រផលិតគ្រឿងបង្គុំអេឡិចត្រូនិច អេសតិច ខបភើរេសិន (ខេមបូឌា)"

ប្រការ៣៖ ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

ប្រការ៤៖ មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព ០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

ប្រការ៥៖ ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៦៖ ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៧៖ ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៨៖ ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៩៖ ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១០៖ ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១១៖ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១២៖ លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

ប្រការ១៣៖ ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ប្រការ១៤: ប្រកាសលេខ ៣១៤ ឧរថ.កឧ.ប្រក ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៣ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រ ផលិតគ្រឿងបង្គុំអេឡិចត្រូនិច របស់ក្រុមហ៊ុន អេសតិច ឧបករណ៍សិន (ខេមបូឌា) ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ១៥៖ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

ប្រការ១៦៖ ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

រដ្ឋលេខាធិការ

ហេង សុខគង់

ចម្លងជូន៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- សាលារាជធានីភ្នំពេញ
- មន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ "ដើម្បីជូនជ្រាប"
- ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ០៩៥ ឧស[illegible]-០៧

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មិនា ឆ្នាំ២០១៧

ប្រកាសបង្កើតរោងចក្រ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តី ពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំការអនុញ្ញាតបង្កើតសាខារោងចក្រ កាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន អលវីនថេក ហ្គាម៉ិន មេនូហ្វេកធីរីង ខប ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧។

សម្រេច

ប្រការ១៖ អនុញ្ញាតឱ្យក្រុមហ៊ុន អលវីនថេក ហ្គាម៉ិន មេនូហ្វេកធីរីង ខប (ALLWINTEX GARMENT MANUFACTURING CORP Ltd.) តំណាងដោយ លោក **TANG ZHAOHUA** បង្កើតសាខារោងចក្រ កាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅ ភូមិសំបួរ សង្កាត់ជង្កោ ខណ្ឌជង្កោ រាជធានីភ្នំពេញ។

ឈ្មោះផលិតផល	**លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code**
សម្លៀកបំពាក់	១៤១០

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

ប្រការ២៖ ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ផ្លាកឈ្មោះរោងចក្រ ៖ " រោងចក្រកាត់ដេរសម្លៀកបំពាក់ អលវីនថេក ហ្គាម៉ិន មេនូហ្វេកធឺរីង ខប សាខាទី១ "

ប្រការ៣៖ ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

ប្រការ៤៖ មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

ប្រការ៥៖ ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៦៖ ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រង់រោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៧៖ ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៨៖ ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់ នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៩៖ ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១០៖ ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១១៖ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រង រោងចក្រ និងសិប្បកម្ម។

ប្រការ១២៖ លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

ប្រការ១៣៖ ម្ចាស់រោងចក្រត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ប្រការ១៤៖ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

ប្រការ១៥៖ ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម
រដ្ឋលេខាធិការ

ហេង សុខគង់

ចម្លងជូន៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- សាលារាជធានីភ្នំពេញ
- មន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ "ដើម្បីជូនជ្រាប"
- ដូចប្រការ១៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ០៩៦ ឧស.ការ.ប្រក.០៣

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០១៧

ប្រកាសបង្កើតរោងចក្រ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំការអនុញ្ញាតបង្កើតរោងចក្រផលិតកាបូបគ្រប់ប្រភេទ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧ របស់ក្រុមហ៊ុន យូម៉ាក ផេស៊ីហ្វិក (ខេមបូឌា) ឯ.ក

សម្រេច

ប្រការ១៖ អនុញ្ញាតឱ្យក្រុមហ៊ុន យូម៉ាក ផេស៊ីហ្វិក (ខេមបូឌា) ឯ.ក (YUMARK PACIFIC (CAMBODIA) CO., LTD.) តំណាងដោយ លោក CHEN, LI-CHIEH បង្កើតរោងចក្រផលិតកាបូបគ្រប់ប្រភេទ ដែលមានទីតាំងស្ថិតនៅ ផ្លូវលេខ៨៦K ភូមិត្រពាំងជ្រៃ សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

ឈ្មោះផលិតផល	លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code
កាបូបគ្រប់ប្រភេទ	១៥១២

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

ប្រការ២៖ ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ផ្លាកឈ្មោះរោងចក្រ ៖ " រោងចក្រផលិតកាបូបគ្រប់ប្រភេទ យូម៉ាក ផេស៊ីហ្វីក (ខេមបូឌា) ឯ.ក "

ប្រការ៣៖ ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

ប្រការ៤៖ មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព ០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

ប្រការ៥៖ ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៦៖ ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៧៖ ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៨៖ ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៩៖ ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១០៖ ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួល ហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១១៖ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១២៖ លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

ប្រការ១៣៖ ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ប្រការ១៤៖ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

ប្រការ១៥៖ ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម
រដ្ឋលេខាធិការ

ហេង សុខគង់

ចម្លងជូន៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- សាលារាជធានីភ្នំពេញ
- មន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ១៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft

លេខ : ០៩៧ ឧស.ក.ស.ប.ក.០៣

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០១៧

ប្រកាសបង្កើតរោងចក្រ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្តូរប្រកាសបង្កើតរោងចក្រ កាត់ដេរ ប៉ាក់ និងបោះពុម្ពលើសម្លៀកបំពាក់ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ ២០១៧ របស់ក្រុមហ៊ុន ម៉េង តុង ហ្គាមេន មេនូហ្វេកជើរី

សម្រេច

ប្រការ១៖ អនុញ្ញាតឱ្យក្រុមហ៊ុន ម៉េង តុង ហ្គាមេន មេនូហ្វេកជើរី (MENG TONG GARMENT MANUFACTORY LTD.) តំណាងដោយលោកស្រី FONG KAM CHIK បង្កើតរោងចក្រ កាត់ដេរ ប៉ាក់ និងបោះពុម្ពលើសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅ អគារC ផ្លូវលេខ២១A ភូមិលេខ៣ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល។

ឈ្មោះផលិតផល	លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code
១.សម្លៀកបំពាក់ (កាត់ដេរ)	១៤១០
២.សម្លៀកបំពាក់ (ប៉ាក់)	១៤៣០
៣.សម្លៀកបំពាក់ (បោះពុម្ព)	១៣១៣

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard. Khan Daun Penh. Phnom Penh. Phone : 855-23-211141 . Fax: 855-23-428263

ប្រការ២៖ ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ផ្លាកឈ្មោះរោងចក្រ៖ " រោងចក្រកាត់ដេរសម្លៀកបំពាក់ ម៉េង តុង ហ្គាមេន មេនូហ្វេកជើរី "

ប្រការ៣៖ ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

ប្រការ៤៖ មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព ០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

ប្រការ៥៖ ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៦៖ ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៧៖ ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៨៖ ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៩៖ ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១០៖ ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានទាន់ពេលវេលា ពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១១៖ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១២៖ លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

ប្រការ១៣៖ ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ប្រការ១៤: ប្រកាសលេខ ១០១៦ ឧរថ.កឧ.ប្រក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រ កាត់ដេរ ប៉ាក់ និងបោះពុម្ពលើសម្លៀកបំពាក់ និងលិខិតលេខ ១០៧៣ ឧស.កឧ.លស.០៥ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦ របស់ក្រុមហ៊ុន ម៉េង តុង ហ្គាមេន មេនូហ្វេកជើរី ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ១៥៖ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកណ្តាល និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

ប្រការ១៦៖ ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ឧ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

រដ្ឋលេខាធិការ

ហេង សុខគង់

ចម្លងជូន៖

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-សាលាខេត្តកណ្តាល
-មន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកណ្តាល
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

រក្សាសិទ្ធ និងបោះពុម្ពដោយ
អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
នៃ ទីស្ដីការគណៈរដ្ឋមន្ត្រី